00651605

E53/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី សុំការបញ្ជាក់អះអាងទាក់ទងនឹងបញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូង មានចេតនាសម្រេចលើសំណើរបស់ភាគីទាក់ទងនឹងបណ្តឹងជំទាស់ប្រឆាំងអង្គជំនុំជម្រះសាលាដំបូងទាំងមូលតាមរបៀបណា**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>ផ្ញើជូន៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារទទួល**

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 03 / 2011

ម៉ោង (Time/Heure): 9:45

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមស្នើសុំការបញ្ជាក់ទាក់ទងនឹងបញ្ហាថា តើអង្គជំនុំជម្រះសាលាដំបូងមានចេតនាសម្រេចលើសំណើសុំរបស់ភាគីទាំងអស់ទាក់ទងនឹងបណ្តឹងជិតចិត្តចៅក្រមជាច្រើននៅអង្គជំនុំជម្រះសាលាដំបូងតាមវិធីណា ("បណ្តឹងជិតចិត្ត")។ សំណើនេះចាំបាច់ត្រូវធ្វើឡើងដើម្បីឱ្យមានតម្លាភាព និងដើម្បីជួយការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ។ មេធាវីការពារក្តីលោក អៀង សារី យល់ឃើញថា ខ្លួនមានសិទ្ធិដឹងឮថា តើប្រសិនបើអង្គជំនុំជម្រះសាលាដំបូងកំពុងចាត់វិធានការណ៍ពិតមែន ហើយតើវិធានការណ៍នោះមានអ្វីខ្លះដើម្បីធានាថាដីកា និងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូងផ្តល់ភាពយុត្តិធម៌ខណៈរង់ចាំសេចក្តីសម្រេចលើបណ្តឹងជិតចិត្ត។ ជាពិសេសមេធាវីការពារក្តីលោក អៀង សារី បានស្នើសុំ៖ **ក)** ការបញ្ជាក់តាមកាលវិភាគ និងព័ត៌មានថ្មីៗទាក់ទងនឹងស្ថានភាពនៃបណ្តឹងជិតចិត្ត **ខ)** ការអះអាងបញ្ជាក់ទាក់ទងនឹងថា តើហេតុអ្វីបានជា អង្គជំនុំជម្រះសាលាដំបូង មិនបានផ្អាកដំណើរការនីតិវិធីហើយរង់ចាំសេចក្តីសម្រេចលើបណ្តឹងជិតចិត្ត និង **គ)** ការបញ្ជាក់ទាក់ទងនឹងថា តើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង មានចេតនាពិចារណាក្នុងការផ្អាកបញ្ហានានាៗទាក់ទងនឹងបណ្តឹងជិតចិត្តតាមវិធីណា។

## I **សាវតារ**

១. កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ បានប្តឹងជិតចិត្តចៅក្រម និល ណុន, ចៅក្រម Sylvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavernge និងចៅក្រម ធូ មណី ("បណ្តឹងជិតចិត្តរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ[1]")។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ចៅក្រមទាំងនេះនៅអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ខ្លួននឹងមិនដាក់ការឆ្លើយតបណាមួយទៅនឹងបណ្តឹងជិតចិត្តរបស់ក្រុមមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ [2] ឡើយ។

---

[1] *ករណី អៀង ធីរិទ្ធ* ០០២/១៩-០៩-២០០៧-អវតក/អជសដ, សំណើសុំជិតចិត្តចៅក្រម និល ណុន, ចៅក្រម Sylvia Cartwright, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne និង ចៅក្រម ធូ មណី, ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E28, ERN: 00641075-00641090 ។

[2] *ករណី អៀង ធីរិទ្ធ* ០០២/១៩-០៩-២០០៧-អវតក/អជសដ, អនុស្សរណៈពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅកាន់ប្រធានទៅគណៈកម្មាធិការរដ្ឋបាលតុលាការ, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E28/2, ERN: 00643803-00643804។

២. កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១ ចៅក្រម និល ណុន បានផ្ញើអនុស្សារណៈអន្តរការិយាល័យទៅគណៈកម្មាធិការរដ្ឋបាលតុលាការ (“JAC”) ដោយស្នើសុំឲ្យគណៈកម្មាធិការនេះជ្រើសរើសចៅក្រមកម្ពុជាពីររូប និងចៅក្រមអន្តរជាតិមួយរូបចេញពីចៅក្រមនៅ អវតក ឲ្យមកចូលរួមជាមួយ អង្គជំនុំជម្រះសាលាដំបូងដើម្បីដោះស្រាយបណ្ដឹងដិតចិត្តទាំងនេះ[3]។

៣. កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្ដីលោក នួន ជា បានផ្ញើសំណៅឯកសារថតចម្លងជាភាសាអង់គ្លេស ទៅកាន់ភាគីទាំងអស់ក្នុងសំណុំរឿង០០២ទាក់ទងនឹងបណ្ដឹងដិតចិត្តបន្ទាន់របស់ខ្លួនប្រឆាំងនឹងចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង (“បណ្ដឹងដិតចិត្តរបស់ក្រុមមេធាវីការពារក្ដី នួន ជា”)។ ក្រុមមេធាវីការពារក្ដី នួន ជា បានដាក់បណ្ដឹងដិតចិត្តរបស់ខ្លួននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១[4]។ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ចៅក្រមនានានៅអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ពួកគាត់នឹងមិនដាក់ការឆ្លើយតបណាមួយទៅកាន់បណ្ដឹងដិតចិត្តរបស់ក្រុមមេធាវីការពារក្ដីលោក នួន ជា ឡើយ[5]។

៤. កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ ឧត្ដម គង់ ស្រ៊ឹម ប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ បានផ្ញើអនុស្សារណៈអន្តរការិយាល័យទៅកាន់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង និងសមាជិកទាំងអស់នៃគណៈកម្មាធិការរដ្ឋបាលតុលាការ ដើម្បីជូនដំណឹងដល់ពួកគេថា អង្គចៅក្រមត្រូវបានចុចឈ្មោះរួចស្រេចហើយដើម្បីឲ្យមកសម្រេចលើបណ្ដឹងដិតចិត្តទាំងនេះ ។ អ្នកទាំងនោះរួមមាន ចៅក្រម យូរ ឧត្ដរា ចៅក្រម Claudia Fenz ចៅក្រម ម៉ុង មុន្នីចរិយា ចៅក្រម Katinka Lahuis និងចៅក្រម ហ្មួត វុទ្ធី[6]។

---

[3] *ករណី អៀង ធីរិទ្ធ* ០០២/១៩-០៩-២០០៧-អវតក/អជសដ, អនុស្សរណៈពីចៅក្រម និល ណុន ផ្ញើទៅគណៈកម្មាធិការរដ្ឋបាលតុលាការទាក់ទងនឹងការតែងតាំងចៅក្រមតាមវិធាន ៣៤ (៦) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២ កុម្ភៈ ឆ្នាំ២០១១ ឯកសារ E28/1, ERN: 00643800-00643800 ។

[4] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អជសដ, សំណើជាបន្ទាន់របស់ នួន ជា សុំដិតចិត្តចៅក្រមនានានៃអង្គជំនុំជម្រះសាលាដំបូង , ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E54 ERN: 00641862-00641877 ។

[5] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អជសដ, អនុស្សរណៈពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E54/1, ERN: 00647781-00647782 ។

[6] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អជសដ, អនុស្សរណៈពីឯកឧត្ដម គង់ ស្រ៊ឹម ប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការផ្ញើទៅចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការ

៥. កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមមេធាវីការពារក្ដីលោក អៀង សារី បានផ្ដល់សំណៅឯកសារថតចម្លងជាភាសាអង់គ្លេសអំពីពាក្យសុំរបស់ខ្លួនដើម្បីគាំទ្រ និងធ្វើបណ្ដឹងជំទាស់ចៅក្រមគ្នាទៅកាន់អង្គជំនុំជម្រះសាលាដំបូង និងទៅកាន់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ("បណ្ដឹងជំទាស់របស់មេធាវីការពារក្ដី អៀង សារី") ។ ក្រុមមេធាវីការពារក្ដីលោក អៀង សារី បានដាក់បណ្ដឹងជំទាស់របស់ខ្លួនកាលនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១[7]។ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ថាពួកគាត់នឹងមិនដាក់ការឆ្លើយតបណាមួយទៅនឹងបណ្ដឹងជំទាស់របស់លោក អៀង សារី ឡើយ[8]។

៦. កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ កសព បានឆ្លើយតបទៅនឹងបណ្ដឹងសុំជំទាស់ចៅក្រមទាំងអស់នៅអង្គជំនុំជម្រះសាលាដំបូង ("ចម្លើយតបរបស់ កសព[9]")។ កសព យល់ឃើញថាធាតុផ្សំដែលបង្កើតឲ្យមានការលេចឡើងនូវភាពលម្អៀង មិនទាន់ត្រូវបានបំពេញនៅឡើយទេ ដូច្នេះបណ្ដឹងជំទាស់ទាំងនេះត្រូវតែបដិសេធចោល[10]។ កាលពីថ្ងៃទី១ ខែមិនា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្ដីលោក អៀង សារី[11] និងក្រុមមេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ[12] បានដាក់ការឆ្លើយតបទៅកាន់ចម្លើយ

---

រដ្ឋបាលតុលាការស្ដីពីការបង្កើតអង្គចៅក្រម អនុវត្តតាមសំណើសុំជំទាស់ប្រឆាំងចៅក្រម ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E28/1/1, ERN: 00643802-00643802 ។

[7] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង, ញត្តិរបស់ អៀង សារី គាំទ្រដល់សំណើរបស់ អៀង ធីរិទ្ធ និង នួន ជា សុំជំទាស់ចៅក្រមនានានៃអង្គជំនុំជម្រះសាលាដំបូង និងញត្តិរបស់ អៀង សារី សុំចូលរួមជាមួយសំណើរបស់ អៀង ធីរិទ្ធ សុំដាក់ជំនួសចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយចៅក្រមបំរុង ឬ ចៅក្រមបន្ថែមដែលត្រូវជ្រើសរើសដោយគណៈកម្មាធិការរដ្ឋបាលតុលាការ ដើម្បីសម្រេចលើសំណើសុំជំទាស់ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E53, ERN: 00643507-00643514 ។

[8] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង, អនុស្សរណៈពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E53/1, ERN: 00647779-00647780 ។

[9] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អជសង, ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា សុំជំទាស់ប្រឆាំងចៅក្រម ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E55, ERN: 00647348-00647355។

[10] ដូចខាងលើ នៅកថាខណ្ឌទី២ ។

[11] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង, ចម្លើយតបរបស់ អៀង សារី ចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា សុំជំទាស់ចៅក្រម, ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/2, 00648827-00648835 ។

00651609



តបរបស់ កសព។ នៅថ្ងៃទី២ ខែមិនា ក្រុមមេធាវីការពារក្ដីលោក នួន ជា បានដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់ កសព[13]។

## II. សំណើ

៧. ក្រុមមេធាវីការពារក្ដីលោក អៀង សារី ស្នើឱ្យមានការបញ្ជាក់តាមរយៈកាលវិភាគ និងព័ត៌មានថ្មីៗទាក់ទងនឹងស្ថានភាពនៃបណ្ដឹងជំទាស់ទាំងនេះ ។ ការស្នើសុំនេះ នឹងនាំឱ្យមានដំណោះស្រាយមួយប្រកបដោយតម្លាភាព។

៨. វិធាន៣៤ (៥) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "ចៅក្រមដែលកំពុងមានបញ្ហាអាចបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្ដីសម្រេចស្ដីពីបណ្ដឹងជំទាស់ ប៉ុន្តែចៅក្រមនោះអាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាននៅគ្រប់ពេលវេលាក្នុងដំណើរការនីតិវិធី" ។ ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង ហាក់បីដូចជានៅតែកំពុងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២[14]។ ក្រុមមេធាវីការពារក្ដីលោក អៀង សារី បានលើកឡើងថា៖ "ដរាបណាបណ្ដឹងជំទាស់មិនទាន់ត្រូវបានគេសម្រេចទេនោះ ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងមិនត្រូវចូលរួមក្នុងបញ្ហាដែលមិនទាន់បានដោះស្រាយ ឬក៏អនុវត្តសកម្មភាពណាមួយដើម្បីត្រៀមរៀបចំចូលរួមក្នុងសំណុំរឿង ០០២ ឡើយ ដើម្បីជៀសវាងកុំឱ្យបញ្ហាទាំងនេះជាប់ប្រឡាក់ប្រឡូកក្នុងករណីដែលក្រោមមកទៀតចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងត្រូវបានគេដកចេញ[15]"។ ក្ដីកង្វល់នេះមិនទាន់ត្រូវបានចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងយកទៅដោះស្រាយនៅឡើយទេ។ ក្នុងករណីដែលចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងត្រូវបានគេដកចេញ បញ្ហានេះគឺបណ្ដាលមកពីអង្គជំនុំជម្រះ

---

[12] *ករណី អៀង ធីរិទ្ធ* ០០២/១៩-០៩-២០០៧-អវតក/អជសដ, ចម្លើយតបរបស់ អៀង ធីរិទ្ធ ចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា សុំជំទាស់ចៅក្រម ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/1, ERN: 00648644-00648647 ។

[13] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក/អជសដ, ចម្លើយតបចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា សុំជំទាស់ចៅក្រម ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/3, ERN: 00648899-00648904 ។

[14] ឧទាហរណ៍ សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសដ សំណើរបស់អៀង សារី សុំដាក់អញ្ញត្រកម្ម ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E51/6, ERN: 00648420-00648421, ដែលចុះហត្ថលេខាដោយប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន ជាចៅក្រមម្នាក់ដែលត្រូវបានជំទាស់ដោយសំណើសុំជំទាស់ប្រឆាំងនឹងចៅក្រម ។

[15] ញត្តិរបស់លោក អៀង សារី នៅកថាខណ្ឌទី ១៥ ។

ដែលសម្រេចលើបណ្តឹងជិតចិត្តនេះយល់ឃើញថាភាពលម្អៀងពិតជាកើតឡើងមែន។ ការចូលរួមរបស់ពួកគាត់កាលពីលើកមុននៅក្នុងបញ្ហាជាច្រើនទាក់ទងនឹងសំណុំរឿង០០២ នឹងធ្វើឱ្យសំណុំរឿង០០២ មានភាពប្រឡាក់ប្រឡូកដោយការលេចឡើងនូវភាពលម្អៀងដែលអាចនឹងធ្វើឱ្យប្រឡាក់ប្រឡូកដល់កេរ្តិ៍ឈ្មោះ អវតក ទាំងមូល។

៩. ក្តីកង្វល់របស់ក្រុមមេធាវីការពារក្តី អៀង សារី ចេះតែកើនឡើង ព្រោះវាមានការស្នើសុំឱ្យដកចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងទាំងអស់ មិនមែនត្រឹមតែចៅក្រមម្នាក់ឡើយ[16]។ ទោះបីជាវិធានផ្ទៃក្នុងចែងថា៖ “ទង្វើដែលបានប្រព្រឹត្តនៅមុនការសម្រេចលើបណ្តឹងជិតចិត្តត្រូវតែចាត់ទុកថាមានសុពលភាពក៏ដោយ[17]” ភាពប្រឡាក់ប្រឡូកអូសបន្លាយដែលបណ្តាលមកពីការចូលរួមកាលពីមុនរបស់ចៅក្រមម្នាក់ ដែលក្រោយមកទៀតត្រូវបានគេដកចេញដោយសារតែមានការលេចឡើងនូវភាពលម្អៀង នឹងនៅតែមានដដែល។ កិច្ចដំណើរការនីតិវិធីនឹងត្រូវប្រឡាក់ប្រឡូកដោយដោយការលេចឡើងនូវភាពលម្អៀង ។ ដើម្បីជៀងវាងកុំឱ្យសកម្មភាពណាមួយរបស់ខ្លួនត្រូវបានប្រឡាក់ប្រឡូកដោយការលេចឡើងនូវភាពលម្អៀងក្នុងករណីដែលមានចៅក្រមតែម្នាក់ ឬពីរនាក់ត្រូវបានគេសុំជិតចិត្ត នោះអង្គជំនុំជម្រះសាលាដំបូងអាចបន្តចូលរួមកិច្ចដំណើរការនីតិវិធីដោយគ្មានចៅក្រមដែលបណ្តឹងជិតចិត្តប្រឆាំងរូបគាត់មិនទាន់ត្រូវបានសម្រេច ឬអាចបន្តចូលរួម

---

[16] សូមមើលឧទាហរណ៍ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ) សំណើរបស់ អៀង សារី សុំដាក់ចេញនូវវិធានការណ៍សមស្របទាក់ទងនឹងសេចក្តីថ្លែងការណ៍ជាក់លាក់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជំទាស់ពឹងករាជ្យភាពរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ Katinka Lahuis និងចៅក្រម Rowan Downing, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩, ឯកសារ1, ERN: 00386956-00386968 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង សំណើរបស់ អៀង សារី សុំជិតចិត្តចៅក្រម និល ណុន ដោយសារគាត់បានសារភាព ថាបានទទួលសំណូក និងសំណើសុំឱ្យមានសវនាការជាសាធារណៈ ឬ សុំការអនុញ្ញាតិដើម្បីឆ្លើយតបនឹងអំណះអំណាងណាមួយដែលបង្ហាញឡើងដោយចៅក្រម និល ណុន ដែលជាការឆ្លើយតបរបស់គាត់ចំពោះសំណើនេះ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ឯកសារ 00636122-00636137 ។

[17] វិធាន ៣៤(៩) ។ សូមមើលផងដែរ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/អជសង សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំជិតចិត្តចៅក្រម និល ណុន និង សំណើដែលពាក់ព័ន្ធ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ E5/3, ERN: 00640427-00640435 (សេចក្តីសម្រេច និល ណុន) នៅកថាខណ្ឌទី៤ ដែលចែងថា “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនឹងមិនមោឃភាពទេ បើទោះបីជាចៅក្រមម្នាក់ត្រូវបានជិតចិត្តក៏ដោយ”។

00651611



កិច្ចដំណើរការនីតិវិធីជាមួយចៅក្រមបំរុង[18]។ ក្នុងស្ថានភាពបច្ចុប្បន្ននេះ គឺមិនដូចគ្នាទេ ព្រោះនៅពេលនេះចៅក្រមទាំងអស់នៅអង្គជំនុំជម្រះសាលាដំបូងត្រូវបានគេប្តឹងជំទាស់។ ដើម្បីជៀងវាងកុំឲ្យទង្វើណាមួយរបស់ចៅក្រមទាំងនោះជាប់ប្រឡាក់ប្រឡូក ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងទាំងមូលត្រូវតែលាលែងចេញពីតំណែង។ ប្រសិនបើករណីនេះកើតឡើងមែន នោះវានឹងមិនមានអង្គជំនុំជម្រះសាលាដំបូងទៀតទេ ហើយទោះបីជាចៅក្រមបំរុងអាចជំនួសចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងបានក៏ដោយ ក៏មិនអាចបង្គ្រប់ចំនួនចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងដែលគេតម្រូវឲ្យមានប្រាំនាក់បានដែរ។ ដូច្នេះក្រុមមេធាវីការពារក្តីលោក អៀង សារី សូមលើកហេតុផលថា វានឹងមានសុភវិនិច្ឆ័យតាមផ្លូវតុលាការប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់បណ្តឹងជំទាស់ត្រូវបានដោះស្រាយរួចរាល់[19]។

១០. អង្គជំនុំជម្រះខ្លួនឯងបានចាត់ទុក អវតក "ជាតុលាការគំរូ" ដែលអាចផ្តល់នូវការលើកទឹកចិត្ត និង "សង្កត់ធ្ងន់ពីសារៈសំខាន់នៃការថែរក្សាសុចរិតភាព និងឯករាជ្យភាពផ្នែកតុលាការ[20]" ។ ដោយសារតែកត្តាខាងលើនេះ ចាំបាច់ត្រូវតែមានការបញ្ជាក់ទាក់ទងនឹងបញ្ហាថា តើហេតុអ្វីបានជាចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង មិនបានផ្អាកកិច្ចដំណើរការនីតិវិធីរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ទាំងនេះសិន ។ សំណើសុំការបញ្ជាក់នេះ នឹងផ្តល់ព័ត៌មាន និងតម្លាភាពដោយផ្តល់លទ្ធភាពឲ្យក្រុមមេធាវីការពារក្តីលោក អៀង សារី អាចដឹងថា តើការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងការប្រព្រឹត្តនានាដែលចេះតែបន្តក្នុងសំណុំរឿង០០២ របស់អង្គជំនុំជម្រះសាលាដំបូងរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ មានយុត្តិធម៌សម្រាប់លោក អៀង សារី និងមិនអាចធ្វើឲ្យប្រឡាក់ប្រឡូកនូវកេរ្តិ៍ឈ្មោះរបស់ អវតក ដែលជាតុលាការគំរូរបស់កម្ពុជាដែរឬយ៉ាងណា។ ដូចដែលបានពន្យល់យ៉ាងច្បាស់ដោយចៅក្រម Lord Hewart C.J.ថា៖ "វាមានសារៈសំខាន់ជាសារវន្តដែលថាយើងមិនគ្រាន់តែធ្វើឲ្យមានយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវធ្វើឲ្យគេមើល

---

[18] វិធាននផ្ទៃក្នុងមានលក្ខណៈមិនច្បាស់ទេទាក់ទងនឹងបញ្ហានេះ ។ វិធាន ៣៤ (៥) អនុញ្ញាតិឲ្យចៅក្រម "លាឈប់ដោយស្ម័គ្រចិត្តនៅពេលណាក៏បាននៃដំណើរការនីតិវិធី" ប៉ុន្តែ វិធានផ្ទៃក្នុងចែងមិនច្បាស់ថា តើអង្គជំនុំជម្រះអាចបន្តនីតិវិធីដោយគ្មានចៅក្រមរូបនេះបានដែរ ឬអត់ ឬតម្រូវចៅក្រមបំរុងជំនួសចៅក្រមដែលឈាឈប់នោះ។

[19] ញត្តិរបស់ អៀង សារី នៅកថាខណ្ឌទី ១៥ ។

[20] សំណើសុំជំទាស់ចៅក្រម និល ណុន នៅកថាខណ្ឌទី១៤ ។

00651612



ឃើញថាយុត្តិធម៌ពិតជាមានមែន[21]”។

១១. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង ហាក់បីដូចជាកំពុងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅពេលដែលបណ្ដឹងជិតចិត្តមិនទាន់ត្រូវបានគេសម្រេចនៅឡើយនោះ ហើយដោយសារតែរាល់សេចក្ដីសម្រេចកាលពីលើកមុនរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២ អាចត្រូវបានធ្វើឱ្យប្រឡាក់ប្រឡូក ប្រសិនបើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងត្រូវបានគេរកឃើញថាមានលេចឡើងនូវភាពលម្អៀង នោះក្រុមមេធាវីការពារក្ដីលោក អៀង សារី ស្នើសុំឱ្យមានការបញ្ជាក់ទាក់ទងនឹងបញ្ហាថា តើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងមានចេតនាពិចារណាដល់ការផ្អាកមិនសម្រេចលើបញ្ហានានាៗទាក់ទងនឹងបណ្ដឹងជិតចិត្តទាំងនេះតាមវិធីណា ។ ទោះបីវិធានផ្ទៃក្នុង[22] ចែងថា វានឹងមិនមានឥទ្ធិពលលើទង្វើរតាមផ្លូវតុលាការកាលពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ប៉ុន្ដែនៅក្នុងក្រសែភ្នែករបស់សាធារណៈជន បញ្ហាកាលពីមុនក្នុងសំណុំរឿង០០២ ដែលទាក់ទងនឹងចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង នឹងត្រូវប្រឡូកប្រឡាក់ដោយការលេចឡើងនូវភាពលម្អៀង ។ ដើម្បីកុំឱ្យបញ្ហានេះជិតដាមដោយការលេចឡើងនូវភាពកម្អៀង ការអះអាងបញ្ជាក់ទាក់ទងបញ្ហាថា តើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងមានចេតនាពិចារណាពីការផ្អាកមិនសម្រេចលើបញ្ហានានាទាក់ទងនឹងបណ្ដឹងជិតចិត្ត នឹងនាំឱ្យមានតម្លាភាព ហើយអាចជៀងវាងការប្រឡាក់ប្រឡូកធ្ងន់ធ្ងរដល់កេរ្ដិ៍ដំណែលរបស់ អវតក ដែលបណ្ដាលមកពីភាពលេចឡើងនូវភាពគ្មានអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូង ។ ដូចដែលលោក Lord Diplock បានអះអាងថា “ប្រសិនបើមធ្យោបាយដែលតុលាការបានធ្វើមិនអាចលាក់បាំងពីក្រសែភ្នែក និងត្រជៀករបស់សាធារណៈជនទេនោះ វានឹងផ្ដល់នូវការការពារប្រឆាំងនឹងការប្រព្រឹត្តតាមតែអំពើចិត្ត ឬភាពមិនប្រក្រតីតាមតាមផ្លូវតុលាការ ហើយវាអាចរក្សាទំនុកចិត្តរបស់សាធារណៈជនលើកិច្ចការរដ្ឋបាលរបស់តុលាការថែមទៀតផង[23]”។

**ដូច្នេះ**អាស្រ័យលើហេតុផលដូចដែលបានគូសបញ្ជាក់ពីខាងលើ ក្រុមមេធាវីការពារក្ដីសូមស្នើឱ្យមាន៖

**ក)** ការបញ្ជាក់តាមកាលវិភាគ និងព័ត៌មានថ្មីៗទាក់ទងនឹងស្ថានភាពនៃបណ្ដឹងជិតចិត្ត

[21] *R v. Sussex Justices ex parte McCarthy* [1924], 1 KB 256, ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩២៣។

[22] វិធាន៣៩ (៩) នៃវិធានផ្ទៃក្នុង។

[23] អគ្គព្រះរាជអាជ្ញា តទល់នឹង Leveller Magazine [ឆ្នាំ១៩៧៩] A.C 440, 450។

ខ) ការបញ្ជាក់ទាក់ទងទៅនឹងថាតើហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងមិនបានព្យួរកិច្ចដំណើរការនីតិវិធីរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ និង

គ) ការបញ្ជាក់ទាក់ទងនឹងថាតើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងមានចេតនាពិចារណាពីការព្យួរមិនសម្រេចបញ្ហាទាក់ទងនឹងបណ្ដឹងជំទាស់តាមរបៀបណា។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**